មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីថ្លែងការណ៍

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ប្រារព្ធទិវាអន្តរជាតិ ដើម្បីបញ្ចប់និទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាន

**រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១**

ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២១ គឺជាទិវាអន្តរជាតិដើម្បីបញ្ចប់និទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាន។ ទិវានេះ ជាឱកាសជំរុញឱ្យមានការពិភាក្សាអំពីឧក្រិដ្ឋកម្មប្រឆាំងលើអ្នកសារព័ត៌មាននិងអ្នកធ្វើការនៅក្នុងវិស័យប្រព័ន្ធផ្សព្វផ្សាយដែលមិនទាន់បានទទួលយុត្តិធម៌កន្លងមក និងដើម្បីសម្តែងនូវការគោរពដល់អ្នកសារព័ត៌មានដែលតែងតែប្រថុយប្រថាន ឬបានបាត់បង់អាយុជីវិតក្នុងបុព្វហេតុរាយការណ៍ព័ត៌មានរបស់ខ្លួន។ អ្នកសារព័ត៌មានដើរតួយ៉ាងសំខាន់ក្នុងការផ្តល់នូវព័ត៌មានដែលអាចទុកចិត្តបាន និងត្រឹមត្រូវដល់សាធារណជន។ ដូច្នេះអំពើនិទណ្ឌភាពចំពោះការវាយប្រហារទៅលើអ្នកសារព័ត៌មាន បានបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយកម្រិតការលើកកម្ពស់ការយល់ដឹងរបស់សាធារណជន និងការជជែកវែកញែកក្នុងន័យស្ថាបនាលើប្រធានបទ និងបញ្ហាដែលជាប្រយោជន៍សាធារណៈ។ ទិវានេះក៏ជាឱកាស ដើម្បីរម្លឹកដល់រដ្ឋាភិបាលនៅជុំវិញពិភពលោក ត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការលើកកម្ពស់ និងគោរពសេរីភាពសារព័ត៌មាន ព្រមទាំងបញ្ចប់នូវអំពើនិទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មានផងដែរ។

ចាប់តាំងពីឆ្នាំ១៩៩៤ យ៉ាងហោចណាស់មានអ្នកសារព័ត៌មានចំនួន ១៣នាក់ ត្រូវបានសម្លាប់នៅក្នុងប្រទេសកម្ពុជាដោយសារការបំពេញការងាររបស់ខ្លួន។ នៅក្នុងអំឡុងពេលនៃការស្លាប់របស់ជនរងគ្រោះចំនួន ១២នាក់ គឺកើតឡើងដោយសារតែអ្នកសារព័ត៌មានទាំងនោះធ្វើសេចក្តីរាយការណ៍ព័ត៌មាន ដែលពាក់ព័ន្ធដោយផ្ទាល់ដល់បុគ្គលមានអំណាចនៅកម្ពុជា។ ក្នុងចំណោមជនរងគ្រោះចំនួន ១២នាក់នោះ មានអ្នកសារព័ត៌មានចំនួន ៥នាក់ ធ្វើការឱ្យប្រព័ន្ធផ្សព្វផ្សាយដែលរិះគន់គណបក្សកាន់អំណាច ខណៈដែលអ្នកសារព័ត៌មានចំនួន ៧នាក់ផ្សេងទៀតបានធ្វើការស៊ើបអង្កេត និងរាយការណ៍ពីអំពើពុករលួយពាក់ព័ន្ធនឹងមន្ត្រីជាន់ខ្ពស់នៅក្នុងជួររដ្ឋាភិបាល និងស្ថាប័នយោធា។ មកដល់បច្ចុប្បន្ននេះ ការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព ឯករាជ្យភាព និងតម្លាភាពមិនត្រូវបានដំណើរការដើម្បីនាំជនល្មើសដែលបានប្រព្រឹត្តិបទឧក្រិដ្ឋមកធ្វើការជំនុំជម្រះ ដែលបណ្តាលឱ្យករណីទាំងអស់នេះមិនត្រូវបានដោះស្រាយ ហើយជនរងគ្រោះមិនទាន់ទទួលបាននូវយុត្តិធម៌ ខណៈដែលជនល្មើសនៅតែបន្តរួចផុតពីការផ្តន្ទាទោសចំពោះអំពើឧក្រិដ្ឋរបស់ខ្លួន។

ដើម្បីប្រារព្ធទិវាអន្តរជាតិដើម្បីបញ្ចប់និទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាន ម.ស.ម.ក នឹងរៀបចំយុទ្ធនាការតាមអ៊ីនធឺណិត ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលមានសកម្មភាពផ្សេងៗគ្នា។ ក្នុងយុទ្ធនាការនេះ ម.ស.ម.ក មានគោលបំណងលើកកម្ពស់ការយល់ដឹងអំពីតួនាទីដ៏សំខាន់របស់អ្នកសារព័ត៌មាននៅក្នុងសង្គមប្រជាធិបតេយ្យ និងអំពើនិទណ្ឌភាពដែលកំពុងបន្តរ៉ាំរ៉ៃ

ក្នុងប្រទេសកម្ពុជា រួមទាំងអំពើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មានផងដែរ។ ម.ស.ម.ក នឹងផ្សព្វផ្សាយជាសាធារណៈនូវអំពើនិទណ្ឌភាពទាំងនោះ និងអំពាវនាវឱ្យបញ្ចប់នូវអំពើនិទណ្ឌភាពដែលជនល្មើសនៅតែបន្តរួចផុតពីការផ្តន្ទាទោស។ សូមចូលរួមជាមួយ ម.ស.ម.ក សម្រាប់ព្រឹត្តិការណ៍ដូចខាងក្រោមៈ

- ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ ម.ស.ម.ក នឹងរៀបចំកម្មវិធីវិទ្យុ ដែលពិភាក្សាទៅលើទិវាអន្តរជាតិដើម្បីបញ្ចប់និទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាន។
- ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២១ ម.ស.ម.ក នឹងរៀបចំកិច្ចពិភាក្សាស្តីពីសេរីភាពខាងសារព័ត៌មាន និងនិទណ្ឌភាព ព្រមទាំងចេញនូវសេចក្តីថ្លែងការរួមស្តីអំពីអំពើនិទណ្ឌភាពប្រឆាំងអ្នកសារព័ត៌មានក្នុងប្រទេសកម្ពុជា។
- ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ ម.ស.ម.ក នឹងចេញផ្សាយខិត្តប័ណ្ណព័ត៌មានបច្ចុប្បន្នភាពនៃផែនទីដែលបង្ហាញអំពីករណីឃាតកម្មទាំងអស់លើអ្នកសារព័ត៌មាននៅកម្ពុជា ហើយលោកអ្នកអាចស្វែងរកបាននៅលើគេហទំព័ររបស់យើង (សូមចុចលើតំណភ្ជាប់នេះៈ https://bit.ly/3bd9xP8 )។
- ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ ម.ស.ម.ក នឹងចេញផ្សាយនូវវីដេអូតុក្កតារឿង "**អ្នកបន្តវេន**" ដែលរៀបរាប់ពីកូនប្រុសរបស់អ្នកសារព័ត៌មានដែលត្រូវបានគេសម្លាប់ ព្យាយាមស្វែងរកយុត្តិធម៌ជូនឪពុករបស់ខ្លួន។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង **លោក ហួន ផន អ្នកសម្របសម្រួលគម្រោងការលើកកម្ពស់និងការការពារសេរីភាពខាងការបញ្ចេញមតិនិងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ នៃម.ស.ម.ក** តាមរយៈអ៊ីម៉ែល phorn@cchrcambodia.org ឬ **០៧០ ៧៥៧ ៨៨៤** ។

**ចប់**

## បណ្ណាធិការះ

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") បានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០០២ គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ពន្ធ ដែលធ្វើការលើកកម្ពស់ និងការពារលិទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.ក គឺជាសមាជិកនៃ អង្គការផ្លាស់ប្តូរសេរីភាពបញ្ចេញមតិអន្តរជាតិ (IFEX) ដែលជាបណ្តាញសកលសម្រាប់សេរីភាពនៃការបញ្ចេញមតិ និង CIVICUS ៖ សម្ព័ន្ធពិភពលោកសម្រាប់ការចូលរួមរបស់ពលរដ្ឋ។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការប្រឆាំងទារុណកម្មពិភពលោក (MOCT SOS-Torture Network) និង ជាសមាជិក OECD Watch ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ទទួលបានពានរង្វាន់ពីមូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិ និង សេរីភាព" និងទទួលពានរង្វាន់ ទំនាក់ទំនងសម្រាប់ការផ្លាស់ប្តូរសង្គម មកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងផ្លាស់ប្តូរសង្គម នៅសាកលវិទ្យាល័យឃ្វីនឡែនក្នុងទីក្រុងប្រីសបែន (Brisbane) នៃប្រទេសអូស្ត្រាលី។